# សុន្ទរកថា

# ឯកឧត្តមកិត្តិបណ្ឌិត ពេជ្រ ប៊ុនធិន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ថ្លែងក្នុងពិធីបិទវគ្គបណ្តុះបណ្តាលនិងប្រគល់វិញ្ញាបនបត្រ ជូនកម្មសិក្សាការីវគ្គបណ្តុះបណ្តាលតម្រង់ទិសពង្រឹងសមត្ថភាព ដល់មន្ត្រីរាជការស៊ីវិលក្របខណ្ឌថ្មី នៃក្រសួងមុខងារសាធារណៈ

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៦

- *ឯកឧត្តម លោកជំទាវ គណៈអធិបតី*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលជាវាគ្មិន នៃក្រសួងមុខងារសាធារណៈ*
- *លោក លោកស្រី នាងកញ្ញា ដែលជាកម្មសិក្សាការីទាំងអស់ ជាទីរាប់អាន*
- *អង្គពិធីទាំងមូលជាទីមេត្រី*

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីរីករាយ ដែលបានចូលរួមជាអធិបតីក្នុងពិធីបិទវគ្គបណ្តុះបណ្តាល និងប្រគល់វិញ្ញាបនបត្របញ្ជាក់ការសិក្សាជូនកម្មសិក្សាការីជាមន្ត្រីរាជការក្នុងវគ្គបណ្តុះបណ្តាលតម្រង់ទិសពង្រឹងសមត្ថភាពដល់មន្ត្រីរាជការស៊ីវិលក្របខណ្ឌថ្មី នៃក្រសួងមុខងារសាធារណៈ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអរគុណដល់ឯកឧត្តម **អុល រ៉ូ** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុដែលបានធ្វើរបាយការណ៍បូកសរុបលទ្ធផលវគ្គបណ្តុះបណ្តាល និងសូមកោតសរសើរដល់ក្រុមការងាររបស់អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ដែលបានខិតខំរៀបចំវគ្គបណ្តុះបណ្តាលនេះ ឱ្យទទួលបានលទ្ធផលល្អប្រសើរ ដោយគ្មានការគាំទ្រផ្នែកបច្ចេកទេស ឬហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍឡើយ។ ក្នុងនោះ ខ្ញុំក៏សូមកោតសរសើរចំពោះវាគ្មិនជាថ្នាក់ដឹកនាំ

និងប្រធាននាយកដ្ឋានដែលបានខិតខំធ្វើបទបង្ហាញ និងចែករំលែកបទពិសោធន៍ដល់កម្មសិក្សាការី។ នេះសរបញ្ជាក់ឱ្យឃើញថាមន្ត្រីរាជការរបស់ក្រសួងមុខងារសាធារណៈមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីធ្វើជាសសរទ្រូង និងជាអ្នកបន្តវេនរបស់ក្រសួងសម្រាប់ការងារគ្រប់គ្រងមុខងារសាធារណៈ។

វគ្គបណ្តុះបណ្តាលតម្រង់ទិសពង្រឹងសមត្ថភាពដល់មន្ត្រីរាជការស៊ីវិលក្របខណ្ឌថ្មីនេះរៀបចំឡើងក្នុងគោលបំណងដើម្បីចែករំលែកបទពិសោធន៍ និងចំណេះដឹងដែលអង្គភាពនីមួយៗ បានអនុវត្តនាពេលកន្លងមក រួមមាន៖

- មុខងារ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អង្គភាព
- លិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលក្រសួងមុខងារសាធារណៈសម្រេចបាន
- ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

*ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា និងអង្គពិធីទាំងមូលជាទីមេត្រី*

ក្រសួងមុខងារសាធារណៈ មានបេសកកម្មដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យមុខងារសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍជាតិ ព្រមទាំងស្របតាមការវិវឌ្ឍជាអន្តរជាតិ។

ក្នុងបរិបទនៃសកលភាវូបនីយកម្ម ការរីកចម្រើនខាងផ្នែកបច្ចេកវិទ្យា ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពគឺជារឿងចាំបាច់សម្រាប់មន្ត្រីរាជការគ្រប់រូប ដើម្បីអភិវឌ្ឍសមត្ថភាពឱ្យស្របតាមការរីកចម្រើន ក្នុងតំបន់ និងសកលលោក។ ការបណ្តុះបណ្តាលធនធានមនុស្សរបស់រដ្ឋគឺជាការងារអាទិភាពមួយ ដែលអាចប្រែក្លាយធនធានមនុស្សនៅក្នុងវិស័យសាធារណៈឱ្យកាន់តែមានសមត្ថភាព មានវិជ្ជាជីវៈ និងបំពេញការងារប្រកបដោយប្រសិទ្ធភាព និងផលិតភាព។

ការអភិវឌ្ឍធនធានមន្ត្រីរាជការ ក៏ត្រូវបានយកចិត្តទុកដាក់ធ្វើឱ្យប្រសើរឡើងទាំងសមត្ថភាពជំនាញ និងឥរិយាបថក្នុងការបំពេញការងារផងដែរ។ ឆ្លើយតបទៅនឹងការវិវត្តន៍ឥតឈប់ឈរខាងផ្នែកបញ្ញាញាណ ការរៀបចំវគ្គបណ្តុះបណ្តាលតម្រង់ទិសពង្រឹងសមត្ថភាព

ដល់មន្ត្រីរាជការស៊ីវិលក្របខណ្ឌថ្មីនេះ គឺជាផ្នែកមួយនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា ដែលនៅតែបន្តចាត់ទុកការអភិវឌ្ឍធនធានមនុស្សជាការងារអាទិភាពចម្បងមួយក្នុងចំណោមអាទិភាពចម្បងចំនួន០៤គឺ **ផ្លូវ ទឹក ភ្លើង** និង**មនុស្ស** ក្នុងនោះ ការបណ្ដុះបណ្ដាលបឋមដល់មន្ត្រីដែលបានជ្រើសរើសថ្មីទាំងអស់ ពាក់ព័ន្ធទៅនឹងដំណើរការរបស់ស្ថាប័នរដ្ឋ គោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល នីតិវិធីរដ្ឋបាល និងរចនាសម្ព័ន្ធគ្រប់គ្រងក្រសួង ស្ថាប័ន ជាផ្នែកមួយក្នុងយុទ្ធសាស្ត្រទី៥ នៃគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ នោះគឺ "ផ្ដល់ការបណ្ដុះបណ្ដាលនិងលើកកម្ពស់គុណភាពនៃការបណ្ដុះបណ្ដាល" ។ កម្មវិធីបណ្ដុះបណ្ដាលសម្រាប់មន្ត្រីក្របខណ្ឌថ្មីនាពេលនេះ ស្ដែងឱ្យឃើញពីការយកចិត្តទុកដាក់ក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកាន់តែខ្លាំងឡើងៗ ជាពិសេស ទៅលើការកសាងនិងអភិវឌ្ឍ **មូលធនមនុស្ស** របស់ក្រសួងមុខងារសាធារណៈ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា និងអង្គពិធីទាំងមូលជាទីមេត្រី*

ខ្ញុំចាត់ទុកថា មន្ត្រីរាជការក្របខណ្ឌថ្មីប្រៀបបីដូចជាក្រដាសសស្អាត ដូច្នេះ ការរៀបចំវគ្គបណ្ដុះបណ្ដាលតម្រង់ទិសពង្រឹងសមត្ថភាពដល់មន្ត្រីរាជការស៊ីវិលក្របខណ្ឌថ្មីនេះ គឺពិតជាមានសារៈសំខាន់សម្រាប់កម្មសិក្សាការីទាំងអស់ឱ្យបានយល់ដឹងអំពី៖

- តួនាទី និងបេសកកម្មរបស់ក្រសួងមុខងារសាធារណៈ
- រចនាសម្ព័ន្ធរបស់ក្រសួង
- តួនាទី ភារកិច្ចរបស់អង្គភាពក្រោមឱវាទក្រសួង
- សិទ្ធិ កាតព្វកិច្ច និងឋានានុក្រមរដ្ឋបាលនៅក្នុងការបំពេញការងារ។

ខ្ញុំសង្ឃឹមជឿជាក់ថា តាមរយៈការបណ្ដុះបណ្ដាលលើប្រធានបទទាំង១៧ ដែលបានធ្វើឡើងក្នុងរយៈពេល ៥ ថ្ងៃកន្លងទៅនេះ លោក លោកស្រី និងនាងកញ្ញា ដែលជាកម្មសិក្សាការី ពិតជាទទួលបាននូវចំណេះដឹង និងទស្សនទានថ្មី ព្រមទាំងបទពិសោធន៍បន្ថែម

លើអ្វីដែលមានស្រាប់ពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ។ ខ្ញុំសូមស្នើដល់កម្មសិក្សាការី ទាំងអស់ដែលបានឆ្លងកាត់វគ្គបណ្តុះបណ្តាលនេះត្រូវយកចំណេះដឹង និងបទពិសោធន៍ល្អៗដែលទទួលបានពីការបណ្តុះបណ្តាលនេះទៅប្រើប្រាស់ និងពង្រីកការប្រើប្រាស់ឱ្យបានចំគោលដៅ ព្រមទាំងបន្តខិតខំអភិវឌ្ឍសមត្ថភាពនៅតាមអង្គភាពរបស់ខ្លួនបន្ថែមទៀតតាមដែលអាចធ្វើទៅបាន សំដៅពង្រឹង និងពង្រីកការយល់ដឹងបន្ថែមដើម្បីក្លាយខ្លួនទៅជា ***មូលធនមនុស្ស***ដ៏មានសារៈសំខាន់ សម្រាប់បម្រើឱ្យការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល បម្រើឱ្យការជម្រុញល្បឿនក្នុងដំណើរការអភិវឌ្ឍន៍របស់ប្រទេស និងដើម្បីបម្រើឱ្យការផ្តល់សេវាសាធារណៈជូនប្រជាជនប្រកបដោយគុណភាព ប្រសិទ្ធភាព និងការជឿទុកចិត្តពីប្រជាជន។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា និងអង្គពិធីជាទីមេត្រី***

ក្នុងឱកាសដ៏មានសារៈសំខាន់នេះ ខ្ញុំសូមផ្តាំផ្ញើដល់កម្មសិក្សាការីជាមន្ត្រីរាជការស៊ីវិលក្របខណ្ឌថ្មី ត្រូវខិតខំយកចិត្តទុកដាក់ក្នុងការបំពេញការងារឱ្យបានល្អ និងចងចាំទុកនូវកិច្ចការសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ក្នុងជីវិតជាមន្ត្រីរាជការ យើងត្រូវចងចាំរបស់**០៥យ៉ាង**ដែលនៅជាប់ជាមួយយើងតាំងពីពេលចូលក្របខណ្ឌរហូតដល់ពេលចូលនិវត្តន៍នោះគឺ ឈ្មោះ អត្តលេខក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់
- គោរពសិទ្ធិ និងកាតព្វកិច្ច ជាពិសេសកាតព្វកិច្ចល័ក្ខការណ៍ និងការសំងាត់វិជ្ជាជីវៈ
- បន្តខិតខំអភិវឌ្ឍសមត្ថភាពដើម្បីបង្កើនប្រសិទ្ធភាពក្នុងការបំពេញការងារជូនអង្គភាព ក៏ដូចជាក្រសួងមុខងារសាធារណៈ
- បង្កើតទំនាក់ទំនងល្អ និងពង្រឹងសាមគ្គីភាពផ្ទៃក្នុង
- គោរពវិន័យ និងឋានានុក្រមរដ្ឋបាលនៅក្នុងពេលបំពេញការងារ
- ជាមន្ត្រីរាជការត្រូវការពារឱ្យបាននូវ៖
    - ផលប្រយោជន៍របស់ប្រទេសជាតិ

- ផលប្រយោជន៍សាធារណៈ
- ផលប្រយោជន៍របស់អង្គភាព ក្រសួង ស្ថាប័ន
- និងផលប្រយោជន៍របស់មន្ត្រីរាជការ។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈ និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលតម្រង់ទិសនេះ និងឈានដល់ការប្រគល់វិញ្ញាបនបត្របញ្ជាក់ការសិក្សាជូននាពេលបន្តិចទៀតនេះ។ ជាមួយគ្នានេះ ខ្ញុំក៏សូមកោតសសើរ និងថ្លែងអំណរគុណចំពោះវាគ្មិនជាថ្នាក់ដឹកនាំនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងមុខងារសាធារណៈ ដែលបានខិតខំធ្វើបទបង្ហាញ និងចែករំលែកបទពិសោធន៍ដល់កម្មសិក្សាការី។

ជាទីបញ្ចប់ខ្ញុំសូមថ្លែងអំណរគុណចំពោះគណៈអធិបតី វាគ្មិន កម្មសិក្សាការីទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងពិធីនេះ និងសូមជូនពរឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា សូមប្រកបដោយពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបិទ វគ្គបណ្តុះបណ្តាលតម្រង់ទិសពង្រឹងសមត្ថភាពដល់មន្ត្រីរាជការស៊ីវិលក្របខណ្ឌថ្មីនៃក្រសួងមុខងារសាធារណៈ ចាប់ពីពេលនេះតទៅ៕

*សូមអរគុណ !*